**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៣ សសរ

# សេចក្ដីសម្រេច

## ស្ដីពីការបែងចែកភារកិច្ចរបស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- យោងតាមតម្រូវការការងារចាំបាច់

### សម្រេច

**ប្រការ ១ :** បែងចែកភារកិច្ចជូនទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ដូចតទៅ ៖

| | |
|---|---|
| ១. ឯកឧត្ដម ហ៊ឹម ឆែម | ទទួលបន្ទុកកិច្ចការអភិវឌ្ឍសហគមន៍ជនជាតិដើមភាគតិច និងការងារផ្សេងទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។ |
| ២. ឯកឧត្ដម អង្គ វង្សវឌ្ឍនា | ទទួលបន្ទុកកិច្ចការអភិវឌ្ឍ និងលើកកម្ពស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ជាអនុប្រធានទី ១ នៃក្រុមប្រឹក្សាអ្នកច្បាប់ និងការងារផ្សេងទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។ |
| ៣. ឯកឧត្ដម ត្រាំ អ៊ីវតឹក | ទទួលបន្ទុកកិច្ចការអភិវឌ្ឍ និងលើកកម្ពស់រដ្ឋាភិបាលឌីជីថល និងការងារផ្សេងទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។ |
| ៤. ឯកឧត្ដម ពេជ្រ ប៊ុនធិន | ទទួលបន្ទុកកិច្ចការកសាងសមត្ថភាពមន្ត្រី នៅក្នុងរដ្ឋបាលសាធារណៈ ជាប្រធានគណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈថ្នាក់ជាតិ និងការងារផ្សេងទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។ |

**ប្រការ ២** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣** : ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃចន្ទ ៧ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ១ និង ប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ